00973384

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / 02 / 2014
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

E302/5

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

សាធារណៈ / Public

ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤

**ផ្ញើជូន:** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី:** **ចៅក្រម និល ណុន, ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/ លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **ការបញ្ជាក់បំភ្លឺទាក់ទងទៅនឹងការប្រើប្រាស់ភស្តុតាង និង នីតិវិធីដើម្បីកោះហៅសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញសាជាថ្មីឡើងវិញពីសំណុំរឿង ០០២/០១ សម្រាប់សំណុំរឿង ០០២/០២**

១. អង្គជំនុំជម្រះបានទទួលសំណើសុំរបស់សហព្រះរាជអាជ្ញា ស្ដីពីការប្រើប្រាស់ភស្ដុតាង និងនីតិវិធីក្នុងការកោះហៅសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញសាជាថ្មីឡើងវិញពីសំណុំរឿង ០០២/០១ សម្រាប់សំណុំរឿង ០០២/០២ (E302) ។ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចថា ភស្តុតាងទាំងអស់ដែលត្រូវបានទទួលយកក្នុងសំណុំរឿង ០០២/០១ នឹងត្រូវបានចាត់ទុកថាបានដាក់ដោយត្រឹមត្រូវនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងរួចហើយ ហើយអាចយកមកប្រើប្រាស់បានសម្រាប់សំណុំរឿង ០០២/០២ (E302)។ សហព្រះរាជអាជ្ញាក៏បានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចថា សាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញទាំងអស់ ដែលត្រូវបានស្ដាប់ចម្លើយនៅក្នុងសំណុំរឿង ០០២/០១ អាចនឹងត្រូវបានកោះហៅសាជាថ្មីឡើងវិញនៅក្នុងសំណុំរឿង ០០២/០២ បាន តែក្នុងករណីដែលភាគីស្នើសុំអាចបង្ហាញឱ្យអង្គជំនុំជម្រះជឿជាក់បានថាការសួរដេញដោលបន្ថែមត្រូវធ្វើឡើងដើម្បីជាប្រយោជន៍យុត្តិធម៌។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីគាំទ្រសំណើសុំរបស់សហព្រះរាជអាជ្ញា (E302/3)។

00973385

២. មេធាវីការពារក្ដីលោក នួន ជា យល់ស្របជាមួយនឹងសំណើសុំរបស់សហព្រះរាជអាជ្ញាដែលថា ភស្តុតាងទាំងអស់ដែលត្រូវបានទទួលយកនៅក្នុងសំណុំរឿង ០០២/០១ នឹងត្រូវបានចាត់ទុកថាបានដាក់ដោយត្រឹមត្រូវនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងរួចហើយ ហើយអាចយកមកប្រើប្រាស់បានសម្រាប់សំណុំរឿង ០០២/០២ ដោយស្វ័យប្រវត្តិ។ ទោះជាយ៉ាងនេះក្ដី មេធាវីការពារក្ដី នួន ជា ស្នើសុំថា អង្គជំនុំជម្រះពុំគួរកំណត់លក្ខខណ្ឌពិសេសណាមួយដើម្បីអនុវត្តចំពោះសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលអង្គជំនុំជម្រះបានស្ដាប់ចម្លើយរួចហើយនៅក្នុងសំណុំរឿង ០០២/០១ ទេ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះគួរតែពិចារណាត្រឹមតែថា តើសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញនីមួយៗដែលគ្រោងថានឹងកោះហៅនោះអាចបម្រើគោលបំណងរបស់អង្គជំនុំជម្រះក្នុងការវាយតម្លៃទៅលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២ បានដែរ ឬយ៉ាងណា (E302/2)។

៣. មេធាវីការពារក្ដីលោក ខៀវ សំផន បានជំទាស់ទៅនឹងសំណើសុំទាំងពីររបស់សហព្រះរាជអាជ្ញា។ មេធាវីការពារក្ដីខាងលើបានលើកឡើងថា ការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បានបង្កើតឱ្យមានការជំនុំជម្រះពីរដាច់ដោយឡែកពីគ្នា ដែលតម្រូវឱ្យមានការអនុវត្តនីតិវិធីដដែលឡើងវិញដូចដែលបានអនុវត្តនៅក្នុងសំណុំរឿង ០០២/០១ រួមទាំង ភាពអាចទទួលយកបាន និងភាពពាក់ព័ន្ធនៃភស្តុតាង (ឯកសារ E302/1, កថាខណ្ឌ ៤, ៨, ១៥, ១៦)។ មេធាវីការពារក្ដី ខៀវ សំផន ក៏បានជំទាស់ទៅនឹងការអនុវត្តបទដ្ឋានកម្រិតខ្ពស់មួយក្នុងការកោះហៅសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញនៅក្នុងសំណុំរឿង ០០២/០១ សាជាថ្មីឡើងវិញ សម្រាប់សំណុំរឿង ០០២/០២ ដោយមេធាវីបានស្នើសុំឱ្យអង្គជំនុំជម្រះអនុវត្តបទដ្ឋានដែលមានចែងស្រាប់នៅក្នុងវិធាន ៨៧ នៃវិធានផ្ទៃក្នុងវិញ (ឯកសារ E302/1, កថាខណ្ឌ ៣៣-៣៦)។

៤. សហព្រះរាជអាជ្ញាបានដាក់សារណាតបទៅនឹងចម្លើយតបមេធាវីការពារក្ដី នៅថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៤ (ឯកសារ E302/4)។

៥. ចំពោះការប្រើប្រាស់ភស្តុតាងនៃសំណុំរឿង ០០២/០១ និងសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីលោក ខៀវ សំផន ដែលថា សំណុំរឿង ០០២ នាពេលនេះ ត្រូវបានបំបែកសម្រាប់ការជំនុំជម្រះពីរផ្សេងគ្នា និងដាច់ដោយឡែកពីគ្នានោះ អង្គជំនុំជម្រះសូមរំលឹកឡើងវិញថា ការបំបែកកិច្ចដំណើរការនីតិវិធីនេះគឺជា“មធ្យោបាយរៀបចំសវនាការសុខ្ទសាធ” ក្នុងគោលបំណងតែមួយគត់គឺដើម្បីកែសម្រួលលំដាប់លំដោយ នូវបទចោទប្រកាន់នានាដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានយកមកដាក់ជំនុំជម្រះនិងវិនិច្ឆ័យសេចក្ដី (ឯកសារ E284, កថាខណ្ឌ ៩៨)។ ចាប់តាំងពីដើមដំបូងនៃការ

ជំនុំជម្រះទៅលើសំណុំរឿង ០០២ មក ភាគីទាំងអស់បានទទួលការជូនដំណឹងថា សំណុំរឿង ០០២/០១ នឹងយកមកប្រើប្រាស់សម្រាប់ជាមូលដ្ឋាននៃការជំនុំជម្រះទៅលើបទចោទដែលនៅសេសសល់ក្នុងសំណុំរឿង ០០២ (ឯកសារ E124/7, កថាខណ្ឌ ១០, ឯកសារលេខ E284, កថាខណ្ឌ ១៥)។ អានុភាពនៃការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ របស់អង្គជំនុំជម្រះសាលាដំបូង គឺដើម្បីបំបែកបទចោទផ្សេងៗ ដែលជាធម្មតាត្រូវបានយកមកវិនិច្ឆ័យនៅក្នុងការជំនុំជម្រះតែមួយ ឲ្យទៅជាការជម្រះពីរ ឬច្រើនជាងនេះ ដែលអាចគ្រប់គ្រងបានល្អជាង មិនមែនជាការបង្កើតឲ្យមានការជំនុំជម្រះពីរដាច់ដោយឡែក និងខុសពីគ្នាស្រឡះនោះទេ។ ជាការពិត អង្គជំនុំជម្រះតុលាការកំពូល (អ.ជ.ត.ក) យល់ឃើញថា សំណុំរឿង ០០២ គឺជាការជំនុំជម្រះតែមួយ ដែលបំបែកទៅជាច្រើនផ្នែក ដោយសារការបំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ E284/4/8, កថាខណ្ឌ ៤៣, ៧០)។ ហេតុដូច្នេះ ការអះអាងរបស់មេធាវីការពារក្តីលោក ខៀវ សំផន ត្រង់ចំណុចនេះមិនមានសម្អាងគ្រប់គ្រាន់ឡើយ។

៦. មេធាវីការពារក្តីលោក ខៀវ សំផន អះអាងបន្ថែមទៀតថា យោងទៅលើសាលដីកាចុងក្រោយរបស់ អ.ជ.ត.ក ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនោះ ការអនុវត្តនីតិវិធីសម្រាប់សវនាការ និងភស្តុតាងចាំបាច់ត្រូវធ្វើតាមនីតិវិធីដដែលទាំងអស់ឡើងវិញ។ នៅក្នុងសេចក្តីសម្រេចនោះ អ.ជ.ត.ក បានពិនិត្យទៅលើយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិនានា ដោយធ្វើការពិចារណាទៅលើការបំបែកកិច្ចដំណើរការនីតិវិធីទៅលើបទចោទនានា ហើយបានកត់សម្គាល់ថា ការទទួលយកភស្តុតាងមួយចំនួនអាចតម្រូវឲ្យធ្វើតាមនីតិវិធីដដែលឡើងវិញស្តីពីការទទួលយកភស្តុតាង ឬចំណាត់ការនីតិវិធីមួយចំនួនក៏ត្រូវធ្វើដដែលឡើងវិញដែរ (ឯកសារ E284/4/8, កថាខណ្ឌ ៣៨-៤០)។ ផ្ទុយពីការអះអាងរបស់មេធាវីការពារក្តីលោក ខៀវ សំផន ទាំងសេចក្តីសម្រេចរបស់ អ.ជ.ត.ក និងសេចក្តីសម្រេចដទៃទៀតដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេចរបស់ អ.ជ.ត.ក មិនបានឈានទៅរកការសន្និដ្ឋានដែលថា អង្គជំនុំជម្រះសាលាដំបូងត្រូវតែអនុវត្តនីតិវិធីសវនាការ និងពិនិត្យភស្តុតាងដដែលឡើងវិញចំពោះដំណាក់កាលទីពីរនៃសំណុំរឿងដែលត្រូវបានបំបែកនេះទេ។ តាមពិតទៅបញ្ហានេះមិនត្រូវបានបង្ហាញឲ្យបានគ្រប់ជ្រុងជ្រោយនោះឡើយ។

៧. ដូចបានលើកឡើងខាងលើរួចមកហើយ កិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២/០២ គឺជាការបន្តកិច្ចដំណើរការនីតិវិធីពីសំណុំរឿង ០០២/០១។ ភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ត្រូវបានភាគីទាំងអស់ធ្វើការពិនិត្យយ៉ាងល្អិតល្អន់ និងជាកម្មវត្ថុនៃលក្ខខណ្ឌតម្រូវដែលមានចែងក្នុងវិធាន ៨៧ នៃវិធានផ្ទៃក្នុង។ វាគ្មានប្រយោជន៍អ្វីត្រូវអនុវត្តចំណាត់ការ

នីតិវិធីទាំងនេះដដែលឡើងវិញនៅក្នុងការជំនុំជម្រះតែមួយនោះទេ។ ផ្អែកតាមមូលហេតុដូចបានលើកឡើងខាងលើ អង្គជំនុំជម្រះសូមបញ្ជាក់ឡើងវិញថា សំណុំរឿង ០០២ ស្ថិតនៅដដែលសម្រាប់ដំណាក់កាលទាំងពីរនៃការជំនុំជម្រះ ហើយភស្តុតាងដែលបានដាក់រួចហើយនៅចំពោះមុខអង្គជំនុំ-ជម្រះនៅក្នុងសំណុំរឿង ០០២/០១ ត្រូវយកមកប្រើប្រាស់ជាមូលដ្ឋានសម្រាប់សំណុំរឿង ០០២/០២។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការប្រើប្រាស់ភស្តុតាងដែលត្រូវបានពិនិត្យរួចហើយនៅក្នុងសំណុំរឿងមួយដែលពាក់ព័ន្ធនឹងភាគីដដែលនៅចំពោះមុខអង្គជំនុំជម្រះដដែល នៅក្នុងសំណុំរឿងតែមួយ ពិតជាបានបំពេញលក្ខខណ្ឌតម្រូវផ្នែកកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងគោរពនូវគោលការណ៍ចំពោះមុខ (វិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង)។

៨. ចំពោះបទដ្ឋានស្តីពី "ផលប្រយោជន៍យុត្តិធម៌" សម្រាប់ការកោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញទាំងអស់ ដែលបានផ្តល់សក្ខីកម្មរួចហើយនៅក្នុងសំណុំរឿង ០០២/០១ សាជាថ្មីឡើងវិញនោះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា បទដ្ឋានបែបនេះមិនចាំបាច់នោះទេ ដោយសារវិធានផ្ទៃក្នុងបានបង្កើតក្របខណ្ឌគតិយុត្តរួចមកហើយ សម្រាប់ការកោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញទាំងអស់ឡើងវិញ ជាពិសេស វិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង។ ក្នុងន័យនេះ អង្គជំនុំជម្រះនឹងពិចារណា ថាតើភាគីនានាត្រូវបានហាមឃាត់ ឬមិនមានឱកាសដើម្បីសាកសួរឱ្យបានពេញលេញទៅលើបុគ្គលណាម្នាក់ ដែលពួកគេមានបំណងស្នើសុំកោះហៅឱ្យចូលខ្លួនមកបំភ្លឺចំពោះមុខអង្គជំនុំជម្រះសាជាថ្មីឡើងវិញ ដោយសារតែវិសាលភាពមានកម្រិតនៃសំណុំរឿង ០០២/០១ ដែរ ឬយ៉ាងណានោះ។ អង្គជំនុំជម្រះសាលាដំបូងសូមរំឭកដល់ភាគីទាំងអស់ថា អនុលោមតាមវិធាន ៨៧(៣)(ក) អង្គជំនុំជម្រះអាចបដិសេធសំណើសុំពិនិត្យភស្តុតាងណាដែលអង្គជំនុំជម្រះយល់ឃើញថា មិនមានភាពពាក់ព័ន្ធ ឬមានភាពច្រំដែល។

៩. ឯកសារនេះគឺជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងឯកសារ E302, E302/1, E302/2, E302/3 និង E302/4 ។